# នាងវិសាខាកសាងព្រះវិហារ

ម្នាលអាវុសោ! ខ្ញុំនិយាយពីរឿងនាងវិសាខាមិនទាន់ចប់នៅឡើយ ទើបសូមត្រឡប់ក្រោយទៅពណ៌នាពីមហាឧបាសិកាអ្នកមានឧបការៈច្រើនចំពោះព្រះពុទ្ធសាសនាម្តងទៀត ។

ពេលដែលនាងកំពុងត្រៀមកសាងអារាមនោះឯង ព្រះដ៏មានព្រះភាគអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ស្តេចទ្រង់យាងទៅកាន់ភទ្ទិយនគរ។ ថ្ងៃមួយពេលដែលសោយភត្តាហារឯផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋីរួចស្រេចហើយក៏បែរព្រះភ័ក្ត្រទៅខាងទិសឧត្តរ ។ ខ្ញុំសូមរៀបរាប់សេចក្តីពិស្តារក្នុងរឿងនេះបន្តិច គឺថាតាមប្រក្រតី ព្រះសាស្តាកាលសោយឯផ្ទះរបស់នាងវិសាខារួចហើយ ក៏យាងចេញតាមទ្វារ ទិសទក្សិណហើយយាងទៅកាន់វត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី បើទទួលភិក្ខាហារឯផ្ទះរបស់អនាថបិណ្ឌិកៈ កាលសោយស្រេចហើយក៏យាងចេញតាមទ្វារទិសខាងកើត ហើយទ្រង់ប្រថាប់ក្នុងវត្តបុព្វារាមរបស់នាងវិសាខា តែបើពេលណាព្រះពុទ្ធអង្គសោយភត្តាហារក្នុងផ្ទះអនាថបិណ្ឌិកៈហើយទ្រង់យាងចេញតាមទ្វារទិសឧត្តរ បរិស័ទទាំងឡាយតែងដឹងច្បាស់ថា ព្រះពុទ្ធអង្គទ្រង់មានព្រះបំណងនឹងចារិកទៅក្នុងទីផ្សេងៗ ដែលយូរៗទើបមានម្តង ។

ពេលនេះកាលនាងវិសាខាជ្រាបថា ព្រះសម្មាសម្ពុទ្ធទ្រង់សោយព្រះក្រយាហារឯផ្ទះអនាថបិណ្ឌិកសេដ្ឋីហើយទ្រង់យាងទ្រង់យាងចេញតាមទ្វារទិសឧត្តរ ទើបចូលទៅគាល់ដោយប្រញាប់ ថ្វាយបង្គំហើយទូលថា "បពិត្រព្រះអង្គដ៏ចំរើន តើព្រះអង្គនឹងទ្រង់យាងទៅកាន់កន្លែងដទៃឬ?"

ពេលព្រះសាស្តាទ្រង់ទទួលហើយទើបទូលបន្តទៀតថា "បពិត្រព្រះអង្គដ៏ចំរើនខ្ញុំព្រះអង្គលះទ្រព្យសម្បត្តិយ៉ាងច្រើនអនេកដើម្បីកសាងអារាមថ្វាយព្រះអង្គ សូមព្រះអង្គមេត្តាយាងត្រឡប់សិន កុំអាលយាងទៅ"

"ម្នាលវិសាខា កុំអី កុំអោយតថាគតត្រលប់អី អោយតថាគតធ្វើកិច្ចរបស់ព្រះពុទ្ធអោយ បានបរិបូរណ៍ចុះ"

នាងវិសាខាពិចារណាថា ព្រះពុទ្ធអង្គច្បាស់ជាមានហេតុពិសេសណាមួយដោយពិត ប្រាកដ ទើបក្រាបទូលថា "ព្រះអង្គដ៏ចំរើនបើដូច្នោះសូមព្រះអង្គទ្រង់ចាត់អោយភិក្ខុអង្គណាមួយ ដែលជាអ្នកដឹងកិច្ចដែលគួរធ្វើនិងមិនគួរធ្វើ ត្រឡប់ផង"

"ម្នាលវិសាខា បើនាងពេញចិត្តភិក្ខុអង្គណា ចូរនាងនិមន្តអង្គនោះទុកចុះ"

នាងវិសាខាគិតថា ក៏ព្រះមហាមោគ្គល្លានជាអ្នកមានឫទ្ធិច្រើនមានអានុភាពច្រើនបើអារាធនាព្រះអង្គអោយនៅនឹងអាចញ៉ាំងអោយការកសាងអារាមបានសំរេចដោយឆាប់រហ័ស គិតដូច្នោះហើយ ទើបអារាធនាព្រះមហាមោគ្គល្លានអោយនិមន្តត្រឡប់ ព្រះមហាថេរៈសំលឹងមើលព្រះបរមសាស្តាជា បែបសុំការអនុញ្ញាតនិងស្តាប់ពុទ្ធបញ្ជា ព្រះសាស្តាទ្រង់អនុញ្ញាតអោយព្រះថេរៈនិងបរិវារនិមន្តត្រឡប់ ។

ក្រោមការជួយជ្រោមជ្រែងរបស់ព្រះអគ្គសាវ័កឆ្វេង ប្រាសាទពីរជាន់ក៏បានសម្រេចយ៉ាងឆាប់រហ័សដែលមានទាំងអស់ ១០០០ បន្ទប់ គឺជាន់ក្រោម ៥០០ បន្ទប់ និងជាន់លើ ៥០០ បន្ទប់ទៀត ។ ព្រះសាស្តាទ្រង់ចារិកទៅអស់រយៈពេល៩ ខែ ទើបទ្រង់យាងត្រឡប់មកវិញ ការកសាងប្រាសាទក៏បានសំរេចក្នុងរយៈពេល៩ ខែដូចគ្នា ។ នាងបានអារាធានាព្រះសាស្តាមួយអន្លើដោយភិក្ខុសង្ឃ គង់ប្រថាប់ ក្នុងប្រាសាទនោះរយៈពេល៤ ខែ ដើម្បីធ្វើពិធីឆ្លងប្រាសាទ កាលព្រះតថាគតទទួលហើយនាងក៏រៀបចំ ថ្វាយអាហារគ្រឿងឧបភោគផ្សេង១ ដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ។

គ្រានោះឯង មានស្ត្រីដែលជាសំលាញ់របស់នាងវិសាខាម្នាក់នាំយកនូវសំពត់ដែលមានតំលៃដល់ ទៅ ១០០០ កហាបណៈ ដើម្បីក្រាលក្នុងប្រាសាទនោះ ទើបប្រាប់ទៅនាងវិសាខាថា "សំលាញ់ ខ្ញុំបាននាំយកសំពត់មួយផ្ទាំងមក តើសំលាញ់អោយខ្ញុំក្រាលត្រង់កន្លែងណា?" នាងវិសាខាឆ្លើយថា "សំលាញ់ បើខ្ញុំនឹងប្រាប់ថាមិនមានកន្លែងអោយក្រាលទេ អ្នកច្បាស់ជាយល់ថា ខ្ញុំមិនប្រាថ្នានឹងអោយអ្នករួមសាងបុណ្យកុសលជាមួយ អញ្ចឹងសូមសំលាញ់រកមើលដោយខ្លួនឯងចុះ ឃើញទីណាសមគួរនឹងក្រាលក៏ក្រាលទីនោះចុះ" នាងដើរពិនិត្យមើលសព្វទីកន្លែងក្នុងប្រាសាទ ក៏មិនឃើញមានកន្លែងណានឹងត្រូវក្រាលដោយសំពត់ដែលមានតំលៃតិចជាង ១០០០ កហាបណៈសោះ នាងមានការខកចិត្តជាខ្លាំងដែលមិនបានចំណែកបុណ្យក្នុងប្រាសាទនោះ ទើបទៅឈរយំនៅក្នុងកន្លែងមួយ ។

ពេលនោះខ្ញុំបានដើរទៅជួបនាងដោយចៃដន្យ ពេលដែលសាកសួរបានដឹងរឿងហេតុអស់ហើយ ខ្ញុំបានណែនាំអោយនាងយកសំពត់នោះទៅក្រាលក្នុងកន្លែងមួយព្រមទាំងលួងលោមថា "ប្អូនស្រីសំពត់ ដែលក្រាលនៅនឹងជើងជណ្តើរនេះមានផលច្រើន មានអានិសង្សមហាសាល ព្រោះភិក្ខុទាំងឡាយពេល លាងជើងហើយតែងតែជូតជើងដោយសំពត់ដែលក្រាលនៅត្រង់នេះ រួចហើយទើបនិមន្តចូលទៅខាងក្នុង" នាងសប្បាយចិត្តឥតឧបមាដែលអាចរកកន្លែងក្រាលសំពត់អោយនាងបានដូចប្រាថ្នា ។ បានឮមកថានាងវិសាខាភ្លេចកំណត់ទីកន្លែងអោយគេក្រាលត្រង់ទីនោះ ។

នាងវិសាខាបានថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះសម្មាសម្ពុទ្ធជាប្រធានអស់រយៈពេល៤ខែ ថ្ងៃចុងក្រោយបាន ប្រគេនចីវរដែលមានសាច់ល្អមានតំលៃថ្លៃ ចំពោះចីវរដែលប្រគេនដល់ភិក្ខុខ្ចីវស្សាបំផុតក៏មានតំលៃដល់ទៅ ១០០០ កហាបណៈ។ ក្នុងសម័យដែលព្រះសម្មាសម្ពុទ្ធទ្រង់គង់ធរមាននៅឡើយ មិនមានស្ត្រីណាធ្វើបុណ្យអោយលើសឬសូម្បីតែស្មើនឹងនាងវិសាខាឡើយ ។

នាសាយណ្ហសម័យ ថ្ងៃដែលធ្វើបុណ្យឆ្លងប្រាសាទចប់សព្វគ្រប់នោះឯង នាងវិសាខាដែលមានបុត្រនិងចៅហែហាមហើយ ដើរប្រទក្សិណជុំវិញប្រាសាទ បន្លឺវាចាចេញមកដោយរីករាយចិត្តថាៈ

-ពេលនេះសេចក្តីប្រាថ្នារបស់យើងដែលនឹងថ្វាយវិហារទានជាប្រាសាទថ្មី មានគ្រឿងលាបលនយ៉ាងល្អសំរេចហើយ ។

-ពេលនេះសេចក្តីប្រាថ្នារបស់យើងដែលនឹងថ្វាយសេនាសនភ័ណ្ឌ មានគ្រែ តាំង និងខ្នើយជាដើមសំរេចបរិបូរណ៍ហើយ ។

-ពេលនេះសេចក្តីប្រាថ្នារបស់យើងដែលនឹងថ្វាយស្លាកភត្តដោយអាហារដ៏ល្អប្រណីតសំរេច បរិបូរណ៍ហើយ ។

-ពេលនេះសេចក្តីប្រាថ្នារបស់យើងដែលនឹងថ្វាយចីវរទានដោយសំពត់ដែលធ្វើពីដែនកាសី សំពត់សំបកឈើនិងសំពត់ធ្វើពីកប្បាសជាដើមសំចេបរិបូរណ៍ហើយ ។

-ពេលនេះសេចក្តីប្រាថ្នារបស់យើងដែលនឹងថ្វាយភេសជ្ជទានមាន ទឹកដោះរាវ ទឹកដោះខាប់ ប្រេងទឹកឃ្មុំ និងទឹកអំពៅជាដើមក៏សំរេចបរិបូរណ៍ហើយ ។

ភិក្ខុទាំងឡាយបានស្តាប់សំលេងរបស់នាងហើយ ក្រាបទូលព្រះសាស្តាថា

"បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះករុណាទាំងឡាយមិនដែលបានឮ ឬបានឃើញនាងវិសាខាច្រៀងសោះតាំងពីដើមមក ថ្ងៃនេះនាងមួយអន្លើដោយបុត្រនិងចៅកំពុងតែដើរច្រៀងប្រទក្សិណប្រាសាទ តើនាងមានមោទនភាព ឬមួយក៏នាងកើតឆ្កួត?" ព្រះសាស្តាត្រាស់ថា "ភិក្ខុទាំងឡាយ! ធីតារបស់តថាគតមិនមែនច្រៀងទេ តែដោយសារអធ្យាស្រ័យក្នុងការបរិច្ចាគរបស់នាងបានពេញបរិបូរណ៍ហើយ ទើបឧទានវាចាដោយសេចក្តីរំភើបរីករាយចិត្ត" ព្រះធម្មរាជាដ៏ឆ្លាតក្នុងការសំដែងធមិ ដើម្បីនឹងទ្រង់ សំដែងធមិអោយកាន់តែពិស្តារទើបត្រាស់ថា "ភិក្ខុទាំងឡាយ! វិសាខា ធីតារបស់តថាគតបង្អោនចិត្តដើម្បីធ្វើកុសលផ្សេងៗ

កាលដែលធ្វើបានសំរេចតាមក្តីប្រាថ្នាក៏រមែងរីករាយសប្បាយចិត្ត ប្រៀបដូចនាយមាលាការ (អ្នកក្រងផ្កា) ដ៏ឆ្លាតប្រមូលបុប្ផជាតិជាច្រើនប្រភេទទុក ហើយក្រងជាកម្រងផ្កាអោយបានស្រស់ស្អាតដូច្នោះ"

ហើយព្រះចមមុនីទ្រង់បញ្ជាក់ទៀតថា

*"នាយមាលាការដ៏ឆ្លាតរមែងធ្វើកម្រងផ្កាបានច្រើនពីគំនរផ្កាដែលបានបេះរក្សាទុកយ៉ាងណា សត្វដែលកើតមកហើយ ហើយត្រូវស្លាប់ទៅវិញ ក៏គប្បីសន្សំបុណ្យកុសលទុកអោយបានច្រើន យ៉ាងនោះដែរ"*

"អាវុសោ! បុគ្គលដែលស្តុកស្តម្ភទៅដោយទ្រព្យ និងសម្បូរដោយសទ្ធានោះរកបានដោយកម្រ អ្នកមានសទ្ធាតែងតែមានទ្រព្យតិច ចំណែកអ្នកមានទ្រព្យច្រើនរមែងខ្វះខាតនូវសទ្ធា ឧបមាដូចជាអ្នកក្រងផ្កាដ៏ឆ្លាតតែខ្វះផ្កាដើម្បីក្រង ចំណែកអ្នកមានផ្កាច្រើនក៏ខ្វះសមត្ថភាពក្នុងការចាត់ចែងក្រងផ្កានោះទៀត ។ ចំណែកនាងវិសាខាប្រកបព្រមបរិបូរណ៍ដោយសទ្ធានិងទ្រព្យ នាងទើបមានបរិបូរណ៍ទាំងទ្រព្យខាងក្នុង និងទ្រព្យខាងក្រៅ "

ថ្ងៃមួយនាងវិសាខាបាននិមន្តព្រះភិក្ខុសង្ឃទុកដើម្បីទៅទទួលភត្តាហារឯគេហដ្ឋានរបស់នាង លុះដល់ពេលហើយនាងទើបប្រើទាសីម្នាក់អោយទៅនិមន្តព្រះសង្ឃ ប៉ុន្តែនាងទាសីបានត្រលប់មកជំរាបនាងវិញថា ក្នុងវត្តជេតពនគ្មានព្រះសង្ឃនៅទេ មានសុទ្ធតែពួកអចេលក៏ (អ្នកបួសអាក្រាតកាយក្នុងសាសនានិគ្រន្ថអន្យតិរ្ថិយ) ទាំងអស់កំពុងតែងូតទឹកភ្លៀង ក្នុងថ្ងៃនោះភ្លៀងធ្លាក់យ៉ាងខ្លាំង ។

កាលនោះព្រះសាស្តាមិនទាន់ទ្រង់បញ្ញត្តិសិក្ខាបទ ហាមភិក្ខុអាក្រាតកាយងូតទឹកទេពេលដែលភ្លៀងធ្លាក់ខ្លាំង ភិក្ខុទាំងឡាយក៏សប្បាយរីករាយចិត្ត ហើយក៏នាំគ្នាស្រាតសំលៀកបំពាក់ស្រង់ទឹកព្រោងព្រាតពេញវត្តជេតពន នាងទាសីមិនដឹងទើបយល់ថាភិក្ខុទាំងអស់នោះសុទ្ធតែជាពួកអចេលក៏ ។

នាងវិសាខាជាមនុស្សឆ្លាតវាងវៃ ពេលបានស្តាប់ដូច្នោះហើយនាងក៏យល់សព្វដំណើរ ទើបអោយទាសីទៅនិមន្តព្រះសង្ឃម្តងទៀត នាងត្រលប់ទៅវត្តជេតពនម្តងនេះភិក្ខុទាំងអស់ក៏ស្រង់ទឹករួចរៀងរាល់អង្គហើយគ្រងចីវររួចជាស្រេច នាងទាសីទើបឃើញមានភិក្ខុនៅពាសពេញវត្តជេតពនហើយក៏ អារាធនាថាដល់វេលាភត្តកិច្ចហើយ ។

ថ្ងៃនោះនាងវិសាខាប្រារព្ធរឿងនេះ ទូលសុំព្រះដ៏មានព្រះភាគថា កាលបើដល់រដូវភ្លៀងចូលវស្សានាងសុំថ្វាយសំពត់សាដកដល់ភិក្ខុទាំងឡាយ ដើម្បីប្រើប្រាស់សំរាប់ស្រង់ទឹក ព្រះពុទ្ធអង្គទ្រង់អនុញ្ញាតអោយ

ថ្វាយបាន ពុទ្ធបរិស័ទទាំងឡាយក៏នាំគ្នាយកតម្រាប់តាម ទើបប្រពៃណីនៃការថ្វាយ សំពត់សាដកមានជាប់ត មករហូតដល់ក្រោយពុទ្ធបរិនិព្វាន ។

ម្នាលអារុំសោ! មនុស្សឆ្លាតរមែងរកឱកាសធ្វើសេចក្តីល្អបានជានិច្ច ពុទ្ធបរិស័ទជំនាន់ក្រោយៗ ជំពាក់បំណុលអំពើល្អរបស់នាងវិសាខា ក្នុងឋានៈជាអ្នកផ្តួចផ្តើមធ្វើនូវអ្វីដែលល្អទុកអោយមនុស្សទាំងឡាយ យកជាគំរូធ្វើដំណើរតាមមកជាច្រើនដោយប្រការយ៉ាងនេះ ។

ពេលព្រះអានន្ទពោលចប់ ឃើញព្រះភិក្ខុកម្ពោជៈនៅតែគង់ស្ងៀមនៅឡើយ ទើបព្រះអង្គមាន ថេរដីកាតទៅទៀតថា " លោកដ៏មានអាយុ! រឿងពុទ្ធចរិយានិងបុគ្គលដែលជាប់ពាក់ព័ន្ធជាមួយនោះមាន ច្រើនហួសពីពណ៌នាអោយអស់ក្នុងពេលតែមួយបាន ខ្ញុំគិតថា តាមរឿងរ៉ាវដែលនាំមកដំណាលឱ្យលោកដ៏ មានអាយុស្តាប់មកប៉ុណ្ណេះក៏ល្មមសមគួរហើយ លោកនៅមានឱកាសអាចបានដឹងនិងសិក្សាក្នុងឱកាសតទៅ ទៀត ម្យ៉ាងទៀតពេលនេះក៏ល្ងាចណាស់ទៅហើយ លោកនិងខ្ញុំក្តូណាមិនទាន់បានស្រង់ទឹកជំរះកាយអោយ បានស្អាតបាតដើម្បីត្រៀមខ្លួនចូលកាន់ទិដ្ឋធម្មសុខវិហារ និង ពិចារណានូវព្រះធម៌អស់ បឋមយាមនៃរាត្រី"

ភិក្ខុកម្ពោជៈក្រោកឡើងអង្គុយច្រហោង លើកដៃប្រណម្យបញ្ចេញវាចាថា សាធុបីដងហើយ ពោលថា "បពិត្រព្រះពុទ្ធអនុជ ជាលាភដ៏ប្រសើរនៃសោតប្រសាទរបស់ខ្ញុំព្រះករុណាដែលបានស្តាប់ពុទ្ធចរិយាពីសំណាក់ ព្រះអង្គដែលប្រៀបដូចជាអង្គស្នងនៃព្រះសាស្តា ខ្ញុំព្រះករុណាសូមចារឹកព្រះគុណ គឺករុណាធម៌របស់ព្រះអង្គ ដោយសេចក្តីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត" ហើយភភិក្ខុកម្ពោជៈក៏ក្រាបថ្វាយបង្គំទៀបព្រះបាទានៃព្រះអានន្ទ ដោយបញ្ចាង្គប្រតិស្ឋាន ( ថ្វាយបង្គំប្រកបដោយអង្គប្រាំ) ។